ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ១៥៤ ប្រក.កសក

# ប្រកាស
## ស្ដីពីការបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់របស់មន្ត្រីរាជការ នៃនាយកដ្ឋាននីតិកម្មកសិកម្ម និង មន្ទីរកសិកម្មខេត្ត ក្រុង

--------

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និង សេវា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨ ស្ដីពីបមាណី និង ការគ្រប់គ្រងសម្ភារៈកសិកម្ម
- បានឃើញប្រកាសរួមលេខ ០២ ប្រក.កយ.កសក.០៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៤ របស់ក្រសួងយុត្តិធម៌ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្ដីពីការដាក់ឱ្យប្រើប្រាស់គំរូលិខិតដោះស្រាយបទល្មើសបមាណីគុណភាពសម្ភារៈកសិកម្ម ដល់មន្ត្រីនគរបាលយុត្តិធម៌ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញប្រកាសលេខ ៣៥៦ ប្រក.កសក.បុ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននីតិកម្មកសិកម្ម

-បានឃើញប្រកាសលេខ ៤២៩ ប្រក.កសក.បុ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និង ការ ប្រព្រឹត្តទៅ របស់មន្ទីរកសិកម្ម ខេត្ត ក្រុង

-បានឃើញសារាចរណែនាំលេខ ៣៨៥ សរណន.កសក ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការណែនាំ ការអនុវត្តអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨

-បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

## សម្រេច

**ប្រការ ១ :** បង្កើត និង កំណត់នូវឯកសណ្ឋាន និង សញ្ញាសម្គាល់ សម្រាប់មន្ត្រីរាជការមានសមត្ថកិច្ចនៃនាយកដ្ឋាន នីតិកម្មកសិកម្ម និង មន្ទីរកសិកម្មខេត្ត ក្រុង ។

**ប្រការ ២ :** ឯកសណ្ឋាន និង សញ្ញាសម្គាល់នេះសម្រាប់ប្រើប្រាស់ក្នុងពេលប្រតិបត្តិការត្រួតពិនិត្យបមាណីគុណភាពសម្ភារៈ កសិកម្ម ចូលរួមសវនាការនៅតុលាការ និងក្នុងពិធីផ្លូវការផ្សេងៗទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៣ :** ឯកសណ្ឋានសម្រាប់មន្ត្រីត្រួតពិនិត្យបមាណីគុណភាពសម្ភារៈកសិកម្មត្រូវកំណត់យកក្រណាត់ពណ៌កាគី សាច់ឈើខ្ចី និង បែងចែកតាមតួនាទីដូចខាងក្រោម :

១-ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានមន្ទីរកសិកម្មខេត្ត ក្រុង ប្រធាន អនុប្រធាន ការិយាល័យនៃនាយកដ្ឋាននីតិកម្មកសិកម្ម និង ប្រធាន អនុប្រធានការិយាល័យនីតិកម្មកសិកម្មខេត្ត ក្រុង ដែលទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ។

២-មន្ត្រីជំនាញ ។

**ប្រការ ៤ :** ឯកសណ្ឋានរបស់ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានមន្ទីរកសិកម្មខេត្ត ក្រុង ប្រធាន អនុប្រធានការិយាល័យនៃនាយកដ្ឋាននីតិកម្មកសិកម្ម និង ប្រធាន អនុប្រធានការិយាល័យនីតិកម្មកសិកម្មខេត្ត ក្រុងដែលទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌សម្រាប់បំពេញបេសកកម្មក្នុងប្រតិបត្តិការត្រួតពិនិត្យ បមាណីគុណភាពសម្ភារៈកសិកម្ម ចូលរួមសវនាការនៅតុលាការ និង ពិធីផ្លូវការផ្សេងៗត្រូវកំណត់ដូចខាង ក្រោម :

**ក-ចំពោះបុរស**

១-អាវដៃខ្លី កបើក ប៉ូលស្មា នែកខ្នង មានហោប៉ៅបួន ហោប៉ៅពីរខាងលើដេរបត់ផ្នត់កណ្តាល គម្រប រាងស្លឹកពោធិ៍ ហោប៉ៅពីរខាងក្រោមគ្មានផ្នត់កណ្តាល គម្របរាងចតុកោណកែង ឡេវមានត្រារូបព្រះរាជ សង្ហារពណ៌មាស ។

២-ខោជើងវែងវេងអំពីសាច់ក្រណាត់ និង ពណ៌ដូចអាវ ចង្កេះដេរត ផ្ទេរបង្កប់ជីបភ្លីខាងមុខពីរ មាន ហោប៉ៅបួន ហោប៉ៅខាងក្រោយពីរដេរបង្កប់ គម្របរាងស្លឹកពោធិ៍ និង ហោប៉ៅពីរទៀតនៅចំហៀងដេរបង្កប់តាមផ្ទេរ ។

៣-ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ ។

៤-ខ្សែក្រវាត់ ស្បែកពណ៌ខ្មៅ ។

**ខ.ចំពោះស្ត្រី**

១-អាវម៉ូតដូចបុរស តែកអាវរាងស្ត្រី ។

២-ខោម៉ូតដូចបុរសតែគ្មានហោប៉ៅក្រោយ ឬ សំពត់ហ្សីបសាច់ក្រណាត់ និង ពណ៌ដូចអាវកាត់ស្រុង ក្រោមជង្គង់ ផែកក្រោយ រូតចំហៀង ។

៣-ស្បែកជើងឃ្លុប កខ្លី មានកែង ស្បែកពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ ។

៤-ខ្សែក្រវាត់ ស្បែកពណ៌ខ្មៅ ។

**ប្រការ ៥** : ឯកសណ្ឋានរបស់មន្ត្រីជំនាញសម្រាប់ត្រួតពិនិត្យបមាណីគុណភាពសម្ភារៈកសិកម្ម ចូលរួមសវនាការនៅ តុលាការ និង ពិធីផ្លូវការផ្សេងៗត្រូវកំណត់ដូចខាងក្រោម :

**ក.ចំពោះបុរស**

១-អាវដៃខ្លី ឬ ដៃវែង កខុប ប៉ូលស្វា ហោប៉ៅពីរដេរបត់ផ្នត់កណ្ដាលគម្របរាងស្លឹកពោធិ៍ កាត់ស្រុង ជើងត្រង់ដាក់ក្នុងខោ ។

២-ខោ ស្បែកជើង ខ្សែក្រវាត់ ដូចក្នុងប្រការ៤ ចំណុចក២ ចំណុចក៣ និង ចំណុចក៤នៃប្រកាសនេះ ។

**ខ.ចំពោះស្ត្រី**

១-អាវដៃខ្លី ឬ ដៃវែង កខុប ចោះឡេវចុងក ប៉ូលស្វា ហោប៉ៅពីរដេរបត់ផ្នត់កណ្ដាលគម្របរាង ស្លឹកពោធិ៍ជីបចង្កេះ ។

២-ខោ និង សំពត់ហ្សីប ស្បែកជើង ខ្សែក្រវាត់ ដូចក្នុងប្រការ៤ ចំណុចខ២ ចំណុចខ៣ និង ចំណុចខ៤ នៃ ប្រកាសនេះ ។

**ប្រការ ៦** : មួករបស់មន្ត្រីត្រួតពិនិត្យបមាណីគុណភាពសម្ភារៈកសិកម្មសម្រាប់ប្រើប្រាស់ក្នុងពេលប្រតិបត្តិការ ត្រូវកំណត់ដូចខាងក្រោម :

មួកកាស្កែតមានសាច់ក្រណាត់ និង ពណ៌ដូចខោ-អាវ ក្បាំងពណ៌ខ្មៅ និង មានកណ្ដាប់វិណ្ឌប៉ាន ពណ៌បៃតង ផ្នែកខាងលើកណ្ដាប់វិណ្ឌមានភ្ជាប់ត្រារូបព្រះរាជសង្ហារពណ៌មាសកម្ពស់៧៨មិល្លីម៉ែត្រ ទទឹង៦៨ មិល្លីម៉ែត្រ ។ ផ្នែកខាងមុខក្រោមកណ្ដាប់វិណ្ឌមានកម្រងខ្សែសយពណ៌មាស ចុងខ្សែទាំងសងខាងភ្ជាប់ឡេវត្រា រូបព្រះរាជសង្ហារមួយពណ៌មាស ។

**មួកកាស្កែតមានបួនប្រភេទគឺ :**

**១-ចំពោះប្រធាន អនុប្រធាននាយកដ្ឋាន និង ប្រធាន មន្ទីរកសិកម្មខេត្ត ក្រុង :**

លើជាយក្បាំងពណ៌ខ្មៅរចនាដោយបាច់ផ្កាភ្ញីទេសនៅចំកណ្ដាលនិងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាងប្រាំមួយទងពណ៌មាសទម្រង់ស្នែងក្របីចុងសងខាងដល់ជើងមួក ។ នៅត្រង់កណ្ដាប់វិណ្ឌផ្នែកខាងមុខចំកណ្ដាលរចនាដោយបាច់ផ្កាភ្ញីទេស និង អមដោយក្បាច់សន្លឹកភ្ញីទេសពណ៌មាសទំហំទទឹង២០ មិល្លីម៉ែត្រ ។

**២-ចំពោះអនុប្រធានមន្ទីរកសិកម្មខេត្ត ក្រុង និង ប្រធានការិយាល័យនៅថ្នាក់កណ្ដាល :**

លើជាយក្បាំងពណ៌ខ្មៅរចនាដោយបាច់ផ្កាភ្ញីទេសនៅចំកណ្ដាល និង អមដោយក្បាច់សន្លឹកភ្ញីទេសម្ខាងបួនទងពណ៌មាស ទម្រង់ស្នែងក្របី ។

**៣-ចំពោះអនុប្រធានការិយាល័យនៅថ្នាក់កណ្ដាល និងប្រធាន អនុប្រធានការិយាល័យនៅថ្នាក់ខេត្ត ក្រុង :**

លើជាយក្បាំងពណ៌ខ្មៅរចនាដោយបាច់ផ្កាភ្ញីទេសនៅចំកណ្ដាល និងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាងពីរទងពណ៌មាស ទម្រង់ស្នែងក្របី ។

**៤-ចំពោះមន្ត្រីជំនាញ :**

លើជាយក្បាំងពណ៌ខ្មៅមានវិណ្ឌទំហំ ០៥ មិល្លីម៉ែត្រពណ៌មាសព័ទ្ធវង់ដល់ជើងមួក ។

ប្រភេទ និង រូបភាពមួកកាស្កែតដែលបានកំណត់ក្នុងចំណុចទី១ ចំណុចទី២ ចំណុចទី៣ និង ចំណុចទី៤ នៃប្រការនេះ មានចែងក្នុងឧបសម្ព័ន្ធភ្ជាប់នៃប្រកាសនេះ ។

**ប្រការ ៧** : ស្លាកសញ្ញាសម្គាល់របស់មន្ត្រីរាជការនៃនាយកដ្ឋានីតិកម្មកសិកម្ម និង មន្ទីរកសិកម្មខេត្ត ក្រុង មានដូចខាងក្រោម :

**១- ស្លាកសញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្ដាំ :** ជាសញ្ញាសម្គាល់របស់នាយកដ្ឋាននីតិកម្មកសិកម្ម ។ តួស្លាកសញ្ញានេះធ្វើពីក្រណាត់ ដែលៈ

-មានអង្កត់ផ្ចិត៧០មិល្លីម៉ែត្រ សម្រាប់ដេរភ្ជាប់នៅដើមដៃអាវស្ដាំក្រោមថ្នេរស្មា៥០មិល្លីម៉ែត្រដោយកំណត់យកភ្លីធ្វើជាចំណុចកណ្ដាល

-ផ្ទៃខាងក្នុងមានកម្រងគួរស្រូវ, ពោត និង ផ្កាកប្បាស អមសង្ខាងជារង្វង់ស្នែងក្របី ពណ៌ទឹកមាសរុំព័ទ្ធដោយបូរ ពណ៌ក្រហមលាយខៀវ ជាបីថ្នាក់ជួបគ្នាខាងចុង ដោយមានប្រាសាទកំពូលបីនៅចំកណ្ដាល

- នៅគល់គួរស្រូវ និង ពោត មានកម្រងបូរ ពណ៌ទង់ជាតិ ធ្វៃជាក្បាច់ ដោយមានសរសេរអក្សរកាត់ " **ននក** " ពណ៌ស តំណាងនាយកដ្ឋាននីតិកម្មកសិកម្ម

- នៅក្រោមអក្សរកាត់មានស្ពឺគ្រឿងចក្រ ពណ៌មាស តំណាងឱ្យការវិវឌ្ឍន៍រីកចំរើនរបស់វិស័យកសិឧស្សាហកម្ម

- នៅខាងលើអក្សរកាត់ មានរាងអក្សរ A ពណ៌ពងមាន់ តំណាងឱ្យសំណង់សិល្បការ និង ទ្វារទឹក
- ផ្ទៃក្នុងចំកណ្តាលមាននិមិត្តសញ្ញារោងចក្រ ពណ៌ពងមាន់ កំពុងបញ្ចេញសកម្មភាព ដែលតំណាងឱ្យការវិវឌ្ឍន៍រីកចំរើនរបស់វិស័យកសិកម្ម ផ្តល់វត្ថុធាតុដើមឱ្យរោងចក្រគ្រប់ពេល ដើម្បីផលិតចេញនូវផលិតផល បម្រើសង្គម
- ផ្ទៃក្នុង ផ្នែកខាងក្រោម មានវាលស្រែ ពណ៌បៃតងខ្ចី មានប្រព័ន្ធស្រោចស្រពទឹក តំណាងឱ្យភាពរីកចំរើនវិស័យកសិកម្មលើដំណាំគ្រប់ប្រភេទ
- ផ្ទៃក្នុងផ្នែកខាងក្រោម នៅលើវាលស្រែ មានសៀវភៅផ្ទៃពណ៌ស តែមសងខាងពណ៌ក្រហម ដែលមានចារឹកអក្សរ "**ច្បាប់កសិកម្ម**" នៅសងខាង និង មានខ្សែរបន្ទាត់ចំនួន ១០ ពណ៌ខៀវកាត់ទទឹង ដែលតំណាងឱ្យបណ្តុំលិខិតបទដ្ឋានដែលទាក់ទងវិស័យកសិកម្ម
- ផ្ទៃក្នុង ផ្នែកខាងលើ ពណ៌ផ្ទៃមេឃ មានប្រាំកាំ : កាំទី ១ រូបត្រាក់ទ័រ កាំទី ២ រូបគោ ជ្រូក មាន់ កាំទី ៣ រូបកែវស្ទង់ កាំទី ៤ រូបត្រី កាំទី ៥ រូបដើមឈើ ដែលតំណាងឱ្យការរីកចំរើនលើវិស័យគ្រឿងយន្តកសិកម្ម ចិញ្ចឹមសត្វ ការសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រ និង បរិស្ថានធម្មជាតិ ។

**២-ស្លាកសញ្ញាសម្គាល់ឈ្មោះមន្ត្រីសម្រាប់ពាក់លើគម្របហោប៉ៅអាវស្តាំ :** តួស្លាកសញ្ញាធ្វើពីជ័រប្លាស្ទិច មានផ្ទៃពណ៌បៃតងគូសបន្ទាត់ពណ៌សជុំវិញតួអក្សរពណ៌ស មានបណ្តោយ ១០០ មិល្លីម៉ែត្រ ទទឹង២០ មិល្លីម៉ែត្រ ។ តួស្លាកសញ្ញាត្រូវបានចែកចេញជាពីរផ្នែក ផ្នែកខាងឆ្វេងមានបណ្តោយ២៥ មិល្លីម៉ែត្រ នៅចំកណ្តាលមានស្លាកសញ្ញាសម្គាល់របស់ "**នាយកដ្ឋាននីតិកម្មកសិកម្ម** " មានអង្កត់ផ្ចិត១៥ មិល្លីម៉ែត្រ នៅក្រោមស្លាកសញ្ញានេះមានអក្សរកាត់ " **នន** ឬ **មកសក**" ពណ៌ស ។ ផ្នែកខាងស្តាំមានបណ្តោយ ៧៥ មិល្លីម៉ែត្រមានអក្សរពីរជួរ ជួរទីមួយសរសេរឈ្មោះមន្ត្រីសាមីជាអក្សរខ្មែរមានកម្ពស់អក្សរ៥ មិល្លីម៉ែត្រ និង ជួរទីពីរសរសេរឈ្មោះជាអក្សរឡាតាំង មានកម្ពស់អក្សរ៣ មិល្លីម៉ែត្រ ។

**៣-ស្លាកសញ្ញាសម្គាល់សម្រាប់ព្យួរលើខ្សែគម្របហោប៉ៅអាវស្តាំ :** តួស្លាកសញ្ញាធ្វើពីលោហធាតុរាងសំប៉ែតមានស្លាកសញ្ញាសម្គាល់របស់ "**នាយកដ្ឋាននីតិកម្មកសិកម្ម**" មានអង្កត់ផ្ចិត៤៥ មិល្លីម៉ែត្រ ភ្ជាប់ដោយបន្ទះស្បែក សម្រាប់ព្យួរនៅហោប៉ៅអាវឆ្វេង ។

**៤-ស្លាកសញ្ញាសម្គាល់សម្រាប់ពាក់លើចុងកអាវឆ្វេង-ស្តាំ :** ជាសញ្ញាសម្គាល់របស់នាយកដ្ឋាននីតិកម្មកសិកម្ម ។ តួស្លាកសញ្ញានេះធ្វើពីលោហធាតុដែលមានរាងមូលមានអង្កត់ផ្ចិត ៣០ មិល្លីម៉ែត្រ ។

**ប្រការ ៨ :** ឯកសណ្ឋាន និង សញ្ញាសម្គាល់ ដូចបានកំណត់ក្នុងប្រកាសនេះ ត្រូវបានផ្តល់ដល់មន្ត្រីមានសមត្ថកិច្ចម្នាក់ៗចំនួនពីរ(២)សម្រាប់ សម្រាប់ប្រើប្រាស់ក្នុងរយៈពេលមួយឆ្នាំ ។

**ប្រការ ៩ :** ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម មានភារកិច្ចទទួលខុសត្រូវលើការគ្រប់គ្រង ការបែងចែកជូនដល់មន្ត្រីមានសមត្ថកិច្ចម្នាក់ៗនូវឯកសណ្ឋាន និង សញ្ញាសម្គាល់ ដូចមានកំណត់ក្នុងប្រកាសនេះ ។

**ប្រការ ១០:** ក្នុងពេលបំពេញបេសកកម្ម មន្ត្រីមានសមត្ថកិច្ច ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និង មានលិខិតបញ្ជាបេសកកម្មជាប់នឹងខ្លួន ។

**ប្រការ ១១ :** ជនណាក្លែងបន្លំស្លៀកពាក់ឯកសណ្ឋាន និង សញ្ញាសម្គាល់របស់មន្ត្រីត្រួតពិនិត្យបមាណីគុណភាពសម្ភារៈកសិកម្ម ដូចមានកំណត់ក្នុងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ ១២ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការស្ថិតិនិងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានមន្ទីរកសិកម្មខេត្ត ក្រុង ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០០៥

**រដ្ឋមន្ត្រី**

ចាន់ សារុន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឯកសណ្ឋានសញ្ញាសម្គាល់ របស់សមត្ថកិច្ចត្រួតពិនិត្យបរិមាណគុណភាពសម្ភារៈកសិកម្ម

ឧបសម្ព័ន្ធភ្ជាប់នៃប្រកាសលេខ ...................... ចុះថ្ងៃទី .............. ខែ ............ ឆ្នាំ ២០០



មួកការ៉ស្កេត



សញ្ញាព្យួរលើឡេវគម្របហោប៉ៅអាវស្តាំ



សញ្ញាសម្គាល់ពាក់លើចុងករអាវឆ្វេង_ស្តាំ និង ដេរលើដើមដៃអាវស្តាំ



សញ្ញាសម្គាល់ឈ្មោះមន្ត្រីពាក់លើគម្របហោប៉ៅអាវស្តាំ

# ឯកសណ្ឋានមន្ត្រីជំនាញ

